# រាជរដ្ឋាភិបាលកម្ពុជា

# ក្រសួងផែនការ

## សេចក្តីណែនាំសម្រាប់ការរៀបចំ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

# ២០១៤-២០១៨

# ( ផយអជ ២០១៤-២០១៨ )

**មេសា ឆ្នាំ២០១៣**

# សេចក្តីណែនាំសម្រាប់ការរៀបចំ
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨
# (ផយអជ ២០១៤-២០១៨)

## ១. សេចក្តីផ្តើម

១.១ រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា គឺនឹងចូលកាន់តំណែងបន្តពីនីតិកាលទី៤ គឺប្រហែលជិតដំណាច់ឆ្នាំ២០១៣។ ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជា បានកំណត់រួចមកហើយថា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** (**ផយអជ**) **២០១៤-២០១៨** ត្រូវកំណត់អាណត្តិកាលដូច អាណត្តិរបស់រាជរដ្ឋាភិបាលដែរ គឺដូចទៅនឹង **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ។ សម្រាប់ ការសម្របសម្រួល និង រៀបចំ **ផយអជ ២០១៤-២០១៨** នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយបានផ្តល់នូវការឯកភាពជាគោលការណ៍ឲ្យក្រសួងផែនការ **ជាអ្នកសម្របសម្រួល និង ដឹកនាំ** ការរៀបចំ **ផយអជ ២០១៤-២០១៨** និង ដោយត្រូវមានកិច្ចសហការនិងការចូលរួមជិតស្និទ្ធពីគ្រប់ក្រសួង ស្ថាប័ន និង អ្នកមានចំណែកពាក់ព័ន្ធទាំងអស់។

## ២. ក្របខ័ណ្ឌនៃគោលនយោបាយ

២.១ ក្របខ័ណ្ឌគោលនយោបាយនិងបរិការណ៍នៃការអភិវឌ្ឍ ដែលផ្តល់ការតម្រង់ទិសដល់ **ផយអជ ២០១៤-២០១៨** គឺត្រូវផ្អែកលើមូលដ្ឋានឯកសារនៃក្របខ័ណ្ឌគោលនយោបាយថ្មីៗដែលរាជរដ្ឋាភិបាលកម្ពុជាទើបបានរៀបចំដូចជាៈ

- *១* របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣។
- *២* របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយពិនិត្យមើលពីវឌ្ឍនភាពផ្នែកសង្គម សេដ្ឋកិច្ចកម្ពុជារួមទាំង ការសម្រេចបាន គអសក ឆ្នាំ២០១២។
- *៣* យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដែលក្រសួង ស្ថាប័នបានរៀបចំ ជាពិសេស ចក្ខុវិស័យរបស់ក្រសួង ស្ថាប័ន។
- *៤* កត្តាវិវឌ្ឍតតឈប់ឈរទាំងក្នុងនិងក្រៅប្រទេសដែលកម្ពុជាជួបប្រទះ។
- *៥* កិច្ចខិតខំប្រឹងប្រែងដែលរាជរដ្ឋាភិបាលកម្ពុជាត្រូវបន្តយកចិត្តទុកដាក់ដើម្បីធ្វើឲ្យកម្ពុជាចេញផុតពីស្ថានភាពជាប្រទេសដែលមានចំណូលទាប (LDCs)។

៦ ដើម្បីធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍សេដ្ឋកិច្ច អាស៊ាននាឆ្នាំ២០១៥។

៧ ដើម្បីធ្វើឲ្យសម្រេចបាននូវគោលដៅភាគច្រើននៃ គអសក ២០១៥ និង បន្ទាប់ពីឆ្នាំ ២០១៥។

៨ ដើម្បីដឹកនាំកម្ពុជានៅលើមាគ៌ាមួយសំដៅទៅរកការអភិវឌ្ឍដែលមានភាពគ្របដណ្តប់គ្រប់ជ្រុងជ្រោយនិងប្រកបដោយចីរភាព ហើយជាគោលដៅចុងក្រោយបង្អស់ គឺដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

## ៣. គោលដៅសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា

៣.១ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាជំរុញឲ្យមានការអភិវឌ្ឍសង្គមជាតិមួយដែលអាចធានាឲ្យមានការលើកកម្ពស់ កម្រិតជីវភាពរស់នៅ និង សុខុមាលភាព របស់ប្រជាជនកម្ពុជា។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចំពោះការកសាងសង្គមជាតិមួយដែលមានលទ្ធិប្រជាធិបតេយ្យនិងដែលគ្រប់គ្រងដោយច្បាប់ រួមជាមួយនឹងការធានាឲ្យមានសមធម៌ក្នុងការទទួលបាននូវសិទ្ធិនិងកាលានុវត្តភាពទាំងឡាយ សម្រាប់ប្រជាជនទូទាំងប្រទេស (ជាពិសេស ស្ត្រី កុមារ យុវវ័យ និង ក្រុមជនងាយរងគ្រោះ) ក្នុងគ្រប់ទិដ្ឋភាព ក្នុងនោះរួមមាន សេដ្ឋកិច្ច នយោបាយ និង វប្បធម៌។ រាជរដ្ឋាភិបាលនឹងបន្តទ្រទ្រង់ដល់ដំណើររីកលូតលាស់នៃសេដ្ឋកិច្ចទីផ្សារដែលមានលក្ខណៈបើកចំហ ដោយរៀបចំឲ្យមានគោលនយោបាយនានាដែលបង្កឲ្យមានបរិយាកាសអំណោយផលសម្រាប់ការរីកចម្រើនរបស់សេដ្ឋកិច្ចទីផ្សារ។ ជាពិសេស ចំណុចគន្លឹះសំខាន់ពីរដែលស្នើឡើងនៅក្នុងឯកសារថ្មីនេះ គឺ ***ការអនុវត្ត និងការជំរុញការអនុវត្ត និង កំណើនបៃតង*** ។

៣.២ គោលដៅគន្លឹះសំខាន់ៗ ដែលជាអាទិភាព និង ត្រូវយកចិត្តទុកដាក់ រួមមាន៖

*អភិបាលកិច្ចល្អ៖*

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាបន្តថែរក្សាសន្តិភាព និងស្ថេរភាពនយោបាយ និងមានវិធានការសម្រាប់ការងារអភិបាលកិច្ចល្អ រួមទាំងពង្រឹងការអនុវត្តការងារវិមជ្ឈការនិងវិសហមជ្ឈការ លើកកំពស់អភិបាលកិច្ចការងារសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យឯកជន និង ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន។

*តុល្យភាពម៉ាក្រូសេដ្ឋកិច្ច៖* ត្រូវរក្សាឲ្យបាននូវតុល្យភាពគន្លឹះទាំងបី រួមមាន ជញ្ជីង ពាណិជ្ជកម្ម ថវិកាជាតិ និង អតិផរណា តាមរយៈ៖

- បង្កើនចំណូលឲ្យបាន១៨% នៃ ផសស និង កាត់បន្ថយឱនភាពថវិកាឲ្យស្ថិតនៅក្នុងកម្រិតទាប នៅឆ្នាំ២០១៨។

- បង្កើនការនាំចេញ ដើម្បីកាត់បន្ថយឱនភាពពាណិជ្ជកម្ម ឲ្យស្ថិតនៅក្នុងកម្រិត ២ ឬ ៣% នៃ ផសស ។ បង្កើនការនាំចេញ ជាពិសេស អង្ករ ផលិតផលកសិកម្ម និងឧស្សាហកម្មធុនស្រាល។
- រក្សាអតិផរណាឲ្យនៅក្នុងកម្រិតមួយស្ថិតក្រោម៥%។
- រៀបចំគោលនយោបាយរូបិយវត្ថុដើម្បីគ្រប់គ្រងសេដ្ឋកិច្ច។
- បន្តអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

*កំណើន ផសស និងពិពិធកម្ម៖* ផយអជ បានកំណត់ឲ្យមានកំណើន ផសស ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ។ ដើម្បីសម្រេចបានកំណើននេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិនិត្យលើវិស័យអាទិភាព ដូចខាងក្រោម៖

- ធ្វើទំនើបកម្ម និងពិពិធកម្មដំណាំស្រូវ និងដើម្បីបង្កើនទិន្នផល ដែលមានប្រភពមកពីស្រែ និងចំការ រួមទាំងដំណាំផ្សេងៗ ជាពិសេស កៅស៊ូ តាមរយៈ ការអនុវត្តកំណែទម្រង់ដីធ្លី ការបង្កើតសហគមន៍កសិករ និងអភិវឌ្ឍន៍ពាណិជ្ជកម្មនៃការចិញ្ចឹមសត្វនិងនេសាទសមុទ្រ។
- លើកទឹកចិត្តឲ្យមានការចូលរួមរបស់វិស័យឯកជនឲ្យមានភាពទូលំទូលាយ និងធ្វើទំនើបកម្ម រួមទាំង ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម។
- ពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុ សម្រាប់ការផ្តល់សេវាកម្មឲ្យបានទូលំទូលាយ ដល់តំបន់ជនបទ និងតំបន់ដាច់ស្រយាល។
- បង្កើតឲ្យមានភាពប្រកួតប្រជែង និងឲ្យមានតម្លាភាពទីផ្សារ និង ការបង្កើតការងារ។
- ជំរុញឲ្យមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា៖ ផ្លូវថ្នល់ អគ្គិសនី ប្រព័ន្ធស្រោចស្រព ព័ត៌មានវិទ្យានិងបច្ចេកវិទ្យា។
- ជំរុញវិស័យទេសចរណ៍។

៣.៣ *តុល្យភាពសេដ្ឋកិច្ច៖*

- នៅពេលកម្ពុជាចាកចេញពីបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច ទៅជាប្រទេសដែលមាន*កំណើនសេដ្ឋកិច្ចស្ទុះឡើង*។
- ត្រៀមខ្លួននៅពេលដែលកម្ពុជាធ្វើសមាហរណកម្មទៅក្នុងអាស៊ានពេញលេញ។
- បន្តរក្សានិងបន្ស៊ុំហានានុក្រមឯកសារ ទៅនឹង ផយអជ។
- ពង្រឹងប្រព័ន្ធពាណិជ្ជកម្មបើកចំហ តាមរូបភាព ការធ្វើសេរីភាវូបនីយកម្មនិងការបង្កើតឡើងនូវគោលនយោបាយពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌនៃសមាហរណកម្មថ្នាក់តំបន់និង ថ្នាក់ពិភពលោក ដោយការផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពសំខាន់ៗមួយចំនួន ដូចជា កិច្ច

ព្រមព្រៀងពាណិជ្ជកម្មនិងវិនិយោគ ការអនុវត្តវិធានការសម្រួលពាណិជ្ជកម្ម និង ការកែទម្រង់ច្បាប់ក្នុងក្របខ័ណ្ឌនៃសមាហរណកម្មពាណិជ្ជកម្ម ជាដើម។

- ពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍នានា សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល។

*៣.៤ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា៖*

ប្រទេសកម្ពុជា ត្រូវគិតឲ្យបានច្បាស់លាស់ និងពង្រីកការប្រើប្រាស់បច្ចេកវិទ្យា ឲ្យបានឆាប់ និងសមស្របសម្រាប់ការធ្វើសមាហរណកម្មទៅក្នុង ASEAN និងការអភិវឌ្ឍនៅក្នុងសហស្សវត្សរ៍ទី២១ នេះ។ ចំណុចដែលជាកត្តាសំខាន់សម្រាប់ការងារជាក់ស្តែងនោះគឺត្រូវលើកកំពស់ជំនាញរបស់កម្មករជំនាន់ថ្មីតាមរយៈការអប់រំពួកគេឲ្យបង្កើនចំណេះដឹង និងមានជំនាញច្បាស់លាស់តាមតម្រូវការនិងស្ថានភាពជាក់ស្តែង។

*៣.៥ ការអភិវឌ្ឍមនុស្សនិងការអភិវឌ្ឍសង្គម-វប្បធម៌* ៖ អាទិភាពនានានឹងត្រូវធ្វើការផ្តោតលើ កាត់បន្ថយភាពក្រីក្រនិង វិសមភាព ការអប់រំ និង សុខភាព ដោយផ្តោតជាពិសេសលើ ស្ត្រី កុមារ និង ក្រុមជនងាយរងគ្រោះ។

*ក. ភាពក្រីក្រ និង វិសមភាព* ៖

- កាត់បន្ថយភាពក្រីក្រឲ្យបានយ៉ាងតិច ១ភាគរយ ក្នុងមួយឆ្នាំ និងលើកកំពស់អាហារូបត្ថម្ភ។
- កាត់បន្ថយគម្លាតវិសមភាព ៖ បង្កលក្ខណៈឲ្យប្រជាជនក្នុងបញ្ជាភាគក្រោមបំផុតអាចមានលទ្ធភាពប្រើប្រាស់បានយ៉ាងតិចណាស់ ១០%នៃការប្រើប្រាស់សរុប ដោយឈរលើមូលដ្ឋានមួយប្រកបដោយចីរភាព។
- ដោះស្រាយបញ្ហាវិសមភាពផ្សេងៗទៀត ជាលក្ខណៈ តំបន់ ភេទ អាយុ អប់រំ សុខភាព កាលានុវត្តភាព និងផ្សេងៗ។
- បង្កើតបណ្តាញសុវត្ថិភាពសង្គម។

*ខ. អប់រំ សុខាភិបាល ទឹកស្អាតនិងអនាម័យ* ៖

- កំណត់ចំណុចដៅផ្នែកបរិមាណដែលមានភាពប្រាកដនិយម សម្រាប់ទាំងសិស្សប្រុសទាំងស្រីសម្រាប់កម្រិតសិក្សានីមួយៗ។
- លើកកម្ពស់គុណភាពអប់រំ។
- ពង្រឹងមូលដ្ឋានធនធានមនុស្ស និង បង្កើនសមត្ថភាពជំនាញផ្នែកបច្ចេកវិទ្យា ជាពិសេស ប្រើប្រាស់បច្ចេកវិទ្យាសម្រាប់វិស័យកសិកម្ម និងឧស្សាហកម្ម។
- វិនិយោគលើវិស័យសុខាភិបាល និងអាហារូបត្ថម្ភ ដើម្បីជួយឲ្យសម្រេចបានប្រកបដោយចីរភាពនូវមូលធនមនុស្ស និង ចំណុចដៅទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងគោលដៅអភិ

វឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

- ប្រជាជនទាំងអស់នឹងទទួលបានទឹកស្អាតប្រើប្រាស់។
- លើកកំពស់គោលនយោបាយជាតិប្រជាជន ដោយរាប់បញ្ចូលទាំងការធ្វើបម្លាស់ប្តូរទីលំនៅ ដើម្បីធានាបាននូវសុខភាពល្អ និងមានកម្លាំងពលំមាំមួន។
- សម្រេចបានចំណុចដៅទាំងឡាយរបស់ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង គិតគូរពីការងារដែលត្រូវធ្វើបន្ត នៅក្នុងដំណាក់កាលក្រោយពី គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

*__គ. ការអភិវឌ្ឍសង្គម-វប្បធម៌__ ៖*

- កិច្ចខិតខំប្រឹងប្រែងត្រូវធ្វើឡើងដើម្បី ថែរក្សានិងលើកកម្ពស់កេរ្តិ៍ដំណែលវប្បធម៌និងបេតិកភ័ណ្ឌ របស់ខ្មែរ។
- កិច្ចខិតខំប្រឹងប្រែងត្រូវធ្វើឡើង ដើម្បីជំរុញលើកកម្ពស់តួនាទីរបស់សាសនា នៅក្នុងការពង្រឹងភាពសុខុដុមក្នុងសង្គម។

៣.៦ *បរិស្ថាន* ៖

- បង្កើនប្រកបដោយចីរភាពនូវ ផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើឲ្យបាន៦០% នៃផ្ទៃដីសរុប។
- ជំរុញលើកកម្ពស់បរិស្ថានឲ្យដល់កម្រិតមួយដែលធ្វើឲ្យកម្ពុជាក្លាយជា ***អ្នកទទួលបានឥណទានសុទ្ធ ពីពាណិជ្ជកម្មកាបោន***។

***៣.៧ បញ្ហាអន្តរវិស័យ*** ៖

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់បញ្ហាមួយចំនួនជាបញ្ហាអន្តរវិស័យ គឺ យេនឌ័រ បរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (ការប្រែប្រួលអាកាសធាតុ និង ការគ្រប់គ្រងគ្រោះមហន្តរាយ) និង គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយកិច្ចខិតខំប្រឹងប្រែងត្រូវផ្តោតលើការបញ្ជ្រាបបញ្ហាអន្តរវិស័យទាំងនេះទៅក្នុងគ្រប់វិស័យទាំងអស់ ដូចជា វិស័យសេដ្ឋកិច្ច វិស័យសង្គមកិច្ច និង វិស័យផ្សេងៗទៀត។ សម្រាប់អាហារូបត្ថម្ភ និងពាណិជ្ជកម្ម ក៏ចាត់ទុកជាបញ្ហាអន្តរវិស័យ និងបញ្ហាអន្តរវិស័យផ្សេងៗទៀត អាចនឹងត្រូវកំណត់បន្ថែមទៀតនៅក្នុងដំណាក់កាលបន្ទាប់ ។

ជាមួយគ្នានេះ ការគ្រប់គ្រងបរិស្ថាន និងយុទ្ធសាស្ត្រកំណើនបៃតង ជាបញ្ហាចំបង ដែលរួមទាំងការអភិរក្សព្រៃឈើ និងការគ្រប់គ្រងដីធ្លី គឺជាកត្តារួមចំណែកដ៏សំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ កាត់បន្ថយការប្រើប្រាស់ថាមពល និងលើកកំពស់ទេសចរណ៍ រួមទាំងការរៀបចំ និងធ្វើជាម្ចាស់ផ្ទះសម្រាប់គំនិតផ្តួចផ្តើមលើប្រធានបទថ្មីៗ ។

សម្រាប់ការប្រែប្រួលអាកាសធាតុ គឺដោយផ្អែកលើ គោលនយោបាយជាតិ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០ ដែលទើបប្រកាសផ្សព្វផ្សាយដោយ*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា* កាលពីពេលកន្លងទៅថ្មីៗនេះ គឺមានសារសំខាន់ខ្លាំងណាស់សម្រាប់ក្រសួង ស្ថាប័នទាំងអស់ ក្នុងការកំណត់ពី *ហានិភ័យនៃបម្រែបម្រួលអាកាសធាតុ ដែលប៉ះពាល់ដល់វិស័យរបស់ខ្លួន និងលើកឡើងនូវវិធានការណ៍សកម្មភាពនានា ដើម្បីកាត់បន្ថយនិងទប់ទល់ជាមួយបម្រែបម្រួលអាកាសធាតុ។* សម្រាប់ការរៀបចំ **ផយអវ ២០១៤-២០១៨** នេះក្រសួងផែនការសូមស្នើដល់គ្រប់ក្រសួង ស្ថាប័នទាំងអស់ត្រូវពិនិត្យឲ្យបានច្បាស់លាស់ និងលើកឡើងនូវវិធានការណ៍សកម្មភាពនៅក្នុងវិស័យរបស់ខ្លួននូវចំណុចសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ហានិភ័យ និងកាលានុវត្តភាពនៃបម្រែបម្រួលអាកាសធាតុ ទាំងក្នុងរយៈពេលខ្លី និងវែង។
- សកម្មភាពនានា សម្រាប់ទប់ទល់ជាមួយបម្រែបម្រួលអាកាសធាតុ រួមទាំង គោលនយោបាយ ផែនការ កម្មវិធី និងការសិក្សាស្រាវជ្រាវ។
- ព័ត៌មាន និងតម្រូវការសមត្ថភាព សម្រាប់ទប់ទល់ជាមួយបម្រែបម្រួលអាកាសធាតុ។
- តម្រូវការជំនួយគាំទ្រពីក្រសួង ស្ថាប័នផ្សេងសម្រាប់ទប់ទល់ជាមួយបម្រែបម្រួលអាកាសធាតុ ដូចជា ការរួមគ្នាធ្វើការសិក្សាវាយតម្លៃ និងការសម្របសម្រួលរៀបចំគោលនយោបាយ និងកម្មភាព សម្រាប់ទប់ ទល់ជាមួយបម្រែបម្រួលអាកាសធាតុ។
- វិធានការណ៍ចាំបាច់ សម្រាប់ទប់ទល់ និងកាត់បន្ថយ ផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ។

### *៣.៨ ការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម៖*

ផ្ទៃដីមួយភាគធំដែលត្រូវរងផលប៉ះពាល់ដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ការគម្រាមកំហែងនៃផលប៉ះពាល់គ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនេះ នឹងត្រូវធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០១៣ ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវចំការមីនជាមូលដ្ឋានដែលនឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១២នេះ ហើយការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម គឺជាកិច្ចការមួយដែលរាជរដ្ឋាភិបាលនឹងបន្តដោះស្រាយនៅក្នុងពេលខាងមុខ។

### *៣.៩ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ៖*

ជាមួយនឹងវិស័យសេដ្ឋកិច្ចដែលកាន់តែមានលក្ខណៈស្មុគស្មាញឡើងៗ ការបង្កើតឲ្យមានប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃមួយដែលមានលក្ខណៈប្រមូលផ្តុំ គឺជាការងារចាំបាច់។ ការចាប់ផ្តើមក្នុងលក្ខណៈសាមញ្ញត្រូវបានធ្វើឡើងនៅគ្រប់កម្រិតទាំងអស់ ដូចជា នៅថ្នាក់ជាតិ នៅកម្រិតវិស័យ និង នៅថ្នាក់ក្រោមជាតិ។ កិច្ចខិតខំប្រឹងប្រែងនេះ ត្រូវធ្វើឲ្យមានលក្ខណៈស៊ី

ជម្រៅជាងមុន ដើម្បីធ្វើឲ្យការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃក្លាយជាផ្នែកមួយនៃដំណើរការរបស់ផែនការជាតិ។ កិច្ចខិតខំប្រឹងប្រែងក៏ត្រូវធ្វើឡើងផងដែរ ក្នុងការកំណត់សូចនាករឲ្យបានច្រើនជាងមុនសម្រាប់ធ្វើការវាយតម្លៃពីលទ្ធផល (outcomes) ឧទាហរណ៍ដូចជា កំណើនដែលមានភាពគ្របដណ្តប់ធំទូលាយ (inclusive growth) -- ភាពប្រសើរឡើងនៃអភិបាលកិច្ច (ដើម្បីឆ្លុះបញ្ចាំងឲ្យឃើញពី ការឆ្លើយតប តម្លាភាព និង គណនេយ្យភាព) និង ក្នុងការពង្រឹងមូលដ្ឋានទិន្ន ន័យសម្រាប់សេដ្ឋកិច្ចកម្ពុជា។

## ៤. វិសាលភាព និងខ្លឹមសារ របស់ ផយអជ ២០១៤-២០១៨

**ផយអជ ២០១៤-២០១៨** គឺជាឯកសារជាតិដែលរៀបចំឡើង *មានលក្ខណសាមញ្ញ អាចវាស់វែង ឈានទៅសម្រេចបានគោលដៅ ចំណុចដៅ មានភាពជាក់ស្តែង និងមានពេលវេលាកំណត់ច្បាស់លាស់។* ជាពិសេស ឯកសារនេះ គឺមានដាក់បញ្ចូលនូវ ផែនការកម្មភាពនានាដែលអាចអនុវត្តបាន និងយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច និងវិស័យពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើជាផែនទីចង្អុលផ្លូវសម្រាប់ ឈានទៅសម្រេចបាននូវការអភិវឌ្ឍប្រទេស និងលើកកំពស់ជីភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ក្រសួងផែនការ ដែលជាអ្នកដឹកនាំការងាររៀបចំ **ផយអជ ២០១៤-២០១៨** នេះ នឹងធ្វើការសម្របសម្រួល ពិភាក្សា ជាមួយស្ថាប័នកណ្តាលបីផ្សេងទៀត រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា បន្ថែមទៀត បន្ទាប់ពីពិភាក្សាដោយផ្ទាល់ជា មួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់។ **ផយអជ ២០១៤-២០១៨** នេះ ត្រូវផ្តោតលើ៖

*១.* របាយការណ៍វឌ្ឍនភាពដែលសម្រេចបានមកដល់ពេលបច្ចុប្បន្ន និងបញ្ហាប្រឈមនានា ក្នុងវិស័យនីមួយៗ របស់ក្រសួង ស្ថាប័ន និងជាពិសេស ធ្វើការបញ្ជាក់ឲ្យច្បាស់ផងដែរទាក់ទងទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។

*២.* កំណត់ពីគោលនយោបាយ យុទ្ធសាស្ត្រនានា ដែលត្រូវអនុវត្តក្នុងវិស័យ របស់ក្រសួង ស្ថាប័ន សម្រាប់ពីឆ្នាំ ២០១៤-២០១៨ ដោយផ្អែកលើ ឯកសារនៃ*ក្របខ័ណ្ឌគោលនយោ បាយ* ដែលបានកំណត់រួចហើយ។

*៣.* កំណត់យកឆ្នាំ២០១២ ជាឆ្នាំគោលនៃការរៀបចំ **ផយអជ ២០១៤-២០១៨** និងប្រើប្រាស់**របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ឆ្នាំ២០១១** និង **របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយពិនិត្យមើលពីវឌ្ឍនភាពផ្នែកសង្គម សេដ្ឋកិច្ចកម្ពុជា និងការសម្រេចបាន គួរសេក ឆ្នាំ ២០១២** សម្រាប់ធ្វើជាមូលដ្ឋាន។

កំណត់យកទិន្នន័យឆ្នាំ២០១២ ជាទិន្នន័យជាក់ស្តែង ប៉ាន់ស្មានសម្រាប់ឆ្នាំ២០១៣ និងព្យាករណ៍សម្រាប់ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។

*៤.* ប្រើប្រាស់ទិន្នន័យដែលមានប្រភពមកពីស្ថិតិជាតិ ឬទិន្នន័យរដ្ឋបាលរបស់ក្រសួង ស្ថាប័ន។ ក៏ប៉ុន្តែ ប្រសិនប្រភពទិន្នន័យទាំងពីរខាងលើមិនមានគ្រប់គ្រាន់ ចាំបាច់ពិចារណាស្វែងរកមកពីប្រភពផ្សេងៗ។

*៥.* កំណត់ពីបញ្ហាប្រឈម និងហានិភ័យ ដែលបណ្តាលមកពីកត្តាទាំងពីរ ដែលមានប្រភពមកពីក្នុងស្រុក និងក្រៅស្រុក ដែលជះឥទ្ធិពលដល់ការអនុវត្តយុទ្ធសាស្ត្រ និងកំណត់ពីវិធានការណ៍សម្រាប់កាត់បន្ថយផលប៉ះពាល់។

*៦.* កំណត់ពីវិធានការណ៍គោលនយោបាយកម្រិតម៉ាក្រូ អន្តរវិស័យ និងវិស័យ ព្រមទាំងអាទិភាព កម្មវិធី និងសំណើរគម្រោងថ្មីៗ ដែលសំដៅជំរុញការកាត់បន្ថយភាពក្រីក្រឲ្យបានឆាប់រហ័ស ការសម្រេចបាន គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ការធានាឲ្យមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងការបន្តធានាឲ្យមានកំណើនដែលផ្អែកលើមូលដ្ឋានធំទូលំទូលាយ។

*៧.* កំណត់ពីការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ក្នុងការអនុវត្តទៅតាមសកម្មភាពនិងវិស័យនានាដែលនឹងមានចែងនៅក្នុង **ផយអជ ២០១៤-២០១៨** ដោយរួមទាំងវិស័យឯកជន និងភាពជាដៃគូ។

*៨.* កំណត់បញ្ជីសូចនាករសម្រាប់ធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពតាមវិស័យរបស់ក្រសួង ស្ថាប័ន។

*៩.* ធាតុចូលសម្រាប់ការរៀបចំ **ផយអជ ២០១៤-២០១៨** ពីគ្រប់ក្រសួង ស្ថាប័ន ត្រូវពិនិត្យនិងផ្តល់ការឯកភាពពីរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលជាប្រធានក្រុមការងារដែលបានបង្កើតរួចមកហើយកាលពីការរៀបចំ **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** របស់ក្រសួង ស្ថាប័ននីមួយៗ មុននឹងផ្ញើជូនក្រសួងផែនការ។

*១០.* ដៃគូអភិវឌ្ឍន៍នានា ត្រូវចូលរួមពិភាក្សា និងផ្តល់ធាតុចូលតាមរយៈយន្តការនៃក្រុមការងារបច្ចេកទេសចម្រុះ (TWGs Mechanism)។

*១១.* ធ្វើការប៉ាន់ស្មានពីតម្រូវការថវិកាសម្រាប់អនុវត្តវិស័យរបស់ខ្លួន។

# ៥. ស្ថាប័នទទួលខុសត្រូវ

## ក. __ក្រសួងផែនការ៖__

ក្រសួងផែនការ គឺជាស្ថាប័នដែលទទួលខុសត្រូវក្នុងការដឹកនាំដំណើរការរៀបចំ **ផយអជ ២០១៤-២០១៨** ហើយត្រូវ៖

- ផ្ដល់ការណែនាំផ្នែកបច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីការរៀបចំធាតុចូល និង អំពីដំណើរការរួមនៃការរៀបចំ **ផយអជ ២០១៤-២០១៨**។
- ប្រមែប្រមូលយកធាតុចូលទាំងឡាយ ពីក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់។
- រៀបចំចងក្រង និងកែសម្រួលឯកសារនេះ ដោយផ្អែកលើធាតុចូល សំណើរ និង អនុសាសន៍ទាំងឡាយដែលទទួលបានពីអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ តាមដំណាក់កាលនីមួយៗនៃដំណើរការរៀបចំឯកសារនេះ ។
- ធ្វើការពិគ្រោះយោបល់ និង សម្របសម្រួលយ៉ាងជិតស្និទ្ធ និងទៀងទាត់ជាមួយនឹងស្ថាប័នកណ្ដាលបីផ្សេងទៀត *(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ)* នៅតាមដំណាក់កាលនីមួយៗ នៃដំណើរការរៀបចំឯកសារនេះ។
- រាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជា ពីវឌ្ឍនភាពនៃការអនុវត្តភារៈកិច្ចនេះតាមដំណាក់កាលនីមួយៗនៃដំណើរការរៀបចំឯកសារនេះ។

### ខ. <u>ក្រសួង ស្ថាប័នពាក់ព័ន្ធ</u>

- ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវប្រើប្រាស់ក្រុមការងារដែលបានបង្កើតឡើងរួចមកហើយកាលពីការរៀបចំ **ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣** ដែលដឹកនាំដោយមន្ត្រីជាន់ខ្ពស់មួយរូបចាប់ពីថ្នាក់រដ្ឋលេខាធិការឡើងទៅ ដើម្បីអនុវត្តភារៈកិច្ចនេះ ដោយធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការ។ ក្រុមការងាររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវផ្ដល់មកក្រសួងផែនការនូវធាតុចូលដំបូងរបស់ខ្លួនសម្រាប់ការរៀបចំ **ផយអជ ២០១៤-២០១៨** ដូចបានកំណត់តាមកម្មវិធីការងារខាងក្រោម។
- ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ត្រូវផ្ដល់ឱ្យបានទាន់ពេលនូវធាតុចូលទាំងឡាយដែលមានព័ត៌មានពេញលេញ និង ផ្ដល់កិច្ចសហការដល់ក្រសួងផែនការនៅក្នុងការអនុវត្តភារៈកិច្ចនេះឱ្យបានសមស្របទៅតាម កម្មវិធីការងារដែលបានគ្រោងទុក។ ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវប្រើប្រាស់យន្តការនៃក្រុមការងារបច្ចេកទេសចម្រុះសម្រាប់ការពិភាក្សា និងការផ្ដល់ធាតុចូល។

## ៦. កម្មវិធីការងារ

*មេសា ២០១៣* ក្រសួងផែនការរៀបចំសេចក្ដីណែនាំសម្រាប់ការរៀបចំ **ផយអជ ២០១៤-២០១៨** ដោយផ្អែកលើការសម្រេចរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង សារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

*មេសា- ១៥ មិថុនា ២០១៣* ក្រសួង ស្ថាប័នពាក់ព័ន្ធផ្តល់ធាតុចូលមកក្រសួងផែនការ មិនឱ្យហួសពីកាលបរិច្ឆេទនេះ។

*១៦ មិថុនា-កញ្ញា២០១៣* -ក្រសួងផែនការជួបជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរកធាតុចូលបន្ថែមទៀត និងដើម្បីធ្វើការបញ្ជាក់លើបញ្ហាមួយចំនួនទាក់ទងនឹងធាតុចូលដែលបានទទួល។

- ក្រសួងផែនការរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពីវឌ្ឍនភាពនៃការប្រមូលធាតុចូលសម្រាប់ការរៀបចំ **ផយអឌ ២០១៤-២០១៨** ។

- ក្រសួងផែនការសម្របសម្រួលឱ្យមានកិច្ចប្រជុំរវាងស្ថាប័នកណ្តាលទាំងបួន (*ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិង អភិវឌ្ឍន៍កម្ពុជា និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*) ដើម្បីពិភាក្សានិងផ្តល់ការណែនាំលើការរៀបចំសេចក្តីព្រាងទីមួយ ។

- ក្រសួងផែនការចាប់ផ្តើមដំណើរការរៀបចំសេចក្តីព្រាងទីមួយ ។

*៣០ កញ្ញា ២០១៣* ក្រសួងផែនការសម្របសម្រួលឱ្យមានកិច្ចប្រជុំរវាងស្ថាប័នកណ្តាលទាំងបួន (*ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិង អភិវឌ្ឍន៍កម្ពុជា និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*) ដើម្បីពិភាក្សានិងផ្តល់យោបល់ លើសេចក្តីព្រាងទីមួយ ។

*២០ តុលា ២០១៣* ក្រសួងផែនការផ្ញើសេចក្តីព្រាងទីមួយទៅជូន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណែកពាក់ព័ន្ធដទៃទៀត រួមទាំងដៃគូអភិវឌ្ឍន៍ ដើម្បីសុំការផ្តល់អនុសាសន៍។

*១០ វិច្ឆិកា ២០១៣* ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណែកពាក់ព័ន្ធដទៃទៀត រួមទាំងដៃគូអភិវឌ្ឍន៍ផ្តល់អនុសាសន៍ ទាំងឡាយមកក្រសួងផែនការ មិនឱ្យហួសពីកាលបរិច្ឆេទនេះ។

*២០-៣០ វិច្ឆិកា ២០១៣* - ក្រសួងផែនការរៀបចំកិច្ចប្រជុំអន្តរក្រសួងចំនួនពីរដង ដើម្បីពិភាក្សាលើសេចក្តីព្រាងកែសម្រួល។

-ក្រសួងផែនការរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលអំពីវឌ្ឍនភាពក្នុងការរៀបចំ **ផយអឌ ២០១៤-២០១៨** ដែលមានរហូតមកដល់ពេលនេះ។

*១៥ ធ្នូ ២០១៣* -កិច្ចប្រជុំរវាងស្ថាប័នកណ្តាលទាំងបួន (*ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា និង ឧត្តមក្រុម ប្រឹក្សាសេដ្ឋកិច្ចជាតិ*) ដើម្បីពិភាក្សានិងផ្តល់យោបល់លើសេចក្តីព្រាងចុងក្រោយ មុននឹងផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី។

-ក្រសួងផែនការ ផ្ញើសេចក្តីព្រាងកែសម្រួលចុងក្រោយជូនគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យពិភាក្សា។

*២០ ធ្នូ ២០១៣–មករា ២០១៤* កិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី នឹងផ្តល់ការអនុម័តលើសេចក្តីព្រាង ហើយសេចក្តីព្រាង ដែលបានទទួលការអនុម័តរួចហើយនឹងត្រូវផ្ញើទៅជូនរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីសុំការឯកភាព និង ថ្វាយព្រះមហាក្សត្រដើម្បីសុំការឡាយព្រះហស្តលេខាលើព្រះរាជក្រមសម្រាប់ការប្រកាសឱ្យប្រើផែនការនេះជាច្បាប់។

*មករា ២០១៤* បោះពុម្ព **ផយអជ ២០១៤-២០១៨** បន្ទាប់ពីទទួលការអនុម័តដាក់ឱ្យប្រើជាច្បាប់ដោយព្រះមហាក្សត្ររួចហើយ។

*កុម្ភៈ ២០១៤* ឯកសារបោះពុម្ពរួច នឹងត្រូវធ្វើការបែងចែក។